# ជិះ TriMet អស់លុយតិច




**អ្នកអាចចំណេញរហូតដល់ 72% ពីការជិះ TriMet, Portland Streetcar និង C-TRAN**

| $1.25 | $2.50 | $28 |
|---|---|---|
| សម្រាប់សំបុត្រ 2½ ម៉ោង | សម្រាប់សំបុត្រជិះមួយថ្ងៃ | សម្រាប់សំបុត្រជិះមួយខែ |

## ដើម្បីមានសិទ្ធិ

✓ **អ្នកត្រូវតែមានអាយុចន្លោះពី 18 ទៅ 64 ឆ្នាំ**

✓ **អ្នកត្រូវតែជាអ្នករស់នៅរដ្ឋអូរីហ្គិន**
បើអាសយដ្ឋាននៅលើអត្តសញ្ញាណប័ណ្ណរបស់អ្នកមិនមែនជាអាសយដ្ឋានអូរីហ្គិន អ្នកក៏ត្រូវមានសំបុត្រមួយច្បាប់ វិក្កយបត្រទឹកភ្លើង ឬកិច្ចព្រមព្រៀងជួល/ភតិសន្យា៖

- មានឈ្មោះរបស់អ្នក និងអាសយដ្ឋានអូរីហ្គិនបច្ចុប្បន្នរបស់អ្នក និង
- បច្ចុប្បន្ន (ក្នុងរយៈពេល 30 ថ្ងៃចុងក្រោយ)

✓ **អ្នកត្រូវតែមានប្រាក់ចំណូលសមស្របសម្រាប់ទទួលបានសិទ្ធិ។**
ប្រាក់ចំណូលសមសមស្របសម្រាប់ទទួលបានសិទ្ធិអាចរកបាននៅ **trimet.org/lowincome**

## ភស្តុតាងនៃប្រាក់ចំណូល

**សម្រាប់បុគ្គល** ត្រូវបំពេញលក្ខខណ្ឌ**មួយ**ក្នុងចំណោមលក្ខខណ្ឌដែលមានដូចខាងក្រោម៖

- ការផ្ទៀងផ្ទាត់ប្រភពការងារ/ប្រាក់ឈ្នួល WorkSource
- លិខិតបញ្ជាក់ IRS បច្ចុប្បន្ន ឬលិខិតមិនដាក់ឯកសារ
- ទម្រង់បែបបទ W2 ពីឆ្នាំជាប់ពន្ធថ្មីបំផុត
- ច្បាប់ចម្លងដែលមានចុះហត្ថលេខាលើលិខិតប្រកាសពន្ធសហព័ន្ធបច្ចុប្បន្ន
- លិខិតអត្ថប្រយោជន៍នៃភាពអត់ការងារធ្វើ និងសន្លឹកកន្ទុយប័ណ្ណបើកប្រាក់ឈ្នួលប្រចាំសប្តាហ៍នាពេលបច្ចុប្បន្ន

**ចំពោះគ្រួសារដែលមានសមាជិក 2 នាក់ឬលើសនេះ** ត្រូវមានច្បាប់ថតចម្លងនៃលិខិតប្រកាសពន្ធសហព័ន្ធដែលបានចុះហត្ថលេខា ឬលិខិតបញ្ជាក់ពន្ធ IRS បច្ចុប្បន្នរបស់អ្នក។

អ្នកមានសិទ្ធិដោយស្វ័យប្រវត្តិ ប្រសិនបើអ្នកបានចុះឈ្មោះចូលក្នុងកម្មវិធីមួយក្នុងចំណោមកម្មវិធីទាំងនេះ៖

- Oregon Health Plan (OHP)
- SNAP
- កម្មវិធីជំនួយថាមពល (LIHEAP, OEAP, WAP)
- កម្មវិធីអាហារថ្ងៃត្រង់ឥតគិតថ្លៃ/តម្លៃទាប
- កម្មវិធីជំនួយ HUD
- TANF
- Employment Daycare (ERDC)

## របៀបដាក់ពាក្យ

### ❶ ចុះឈ្មោះតាមអនឡាញ

ដាក់ពាក្យតាមអនឡាញជាមួយនឹងភស្តុតាងនៃប្រាក់ចំណូលនិងអត្តសញ្ញាណប័ណ្ណដែលមានសុពលភាពចេញដោយរដ្ឋាភិបាលតាមរយៈអ៊ីមែល **trimet.org/lowincome**។

អ្នកត្រូវមានសមត្ថភាពក្នុងការផ្ទុកឡើងឯកសារ និង/ឬចូលរួមក្នុងការហៅចូលចុះឈ្មោះតាមវីដេអូ។

### ❷ ទៅយកប័ណ្ណរបស់អ្នក

យកអត្តសញ្ញាណប័ណ្ណ និងវិក្កយបត្ររបស់អ្នកទៅកាន់ការិយាល័យលក់សំបុត្រ TriMet (701 SW 6th Ave, Portland) ពីថ្ងៃចន្ទដល់ថ្ងៃសុក្រពីម៉ោង 8:30 ព្រឹក - 5:30 ល្ងាច។ យើងនឹងថតរូបអ្នក ហើយចេញកាត Hop card ផ្ទាល់ខ្លួនសម្រាប់អ្នក។

210074 KH • 6/21

**សម្រាប់ជំនួយអ្នកបកប្រែភាសា សូមទូរស័ព្ទទៅលេខ 503-238-7433 រួចចុចលេខ 5 ហើយប្រាប់បុគ្គលិកផ្នែកសេវាបំរើអតិថិជននូវភាសាដែលអ្នកនិយាយ ។**